# ការណែនាំរបស់ឪពុកម្ដាយ

## ចំពោះការបំរើផ្នែកការពារក្មេង(CPS)



ការិយាល័យ
អភិបាលកិច្ចកុមារ

នាយកដ្ឋានផ្នែក
បំរើកុមារនឹងគ្រួសារ

## មាតិការរឿង


| ប្រធានបទ | Page |
| --- | --- |
| តើកិច្ចបំរើផ្នែកការពារកុមារជាអ្វី(CPS)? | 2 |
| តើអ្វីជាការធ្វើទុក្ខទោស ឬធ្វេសប្រហែសមិនយកចិត្តទុកដាក់ដល់កុមារ? | 2 |
| តើការិយាល័យ CPS ឮអំពីខ្ញុំដោយរបៀបណា? | 3 |
| តើការិយាល័យ CPS មានសិទ្ធិអ្វីដើម្បីធ្វើសម្ភាសន៍កូនរបស់ខ្ញុំ? | 3 |
| តើនៅពេលណាប៉ូលីសមានការជាប់ទាក់ទងជាមួយ? | 4 |
| តើ "ការការពារឃុំគ្រងជាអ្វី? | 5 |
| តើមានអ្វីកើតឡើងនៅពេលកូនរបស់ខ្ញុំដាក់នៅកន្លែងការពារឃុំគ្រង? | 5 |
| តើកិច្ចបំរើអ្វីដែលអាចមានចំពោះខ្ញុំនឹងគ្រួសាររបស់ខ្ញុំ? | 6 |
| តើប្រព័ន្ធឆ្លើយតបរបៀបផ្សេងទៀតជាអ(ARS)? | 7 |
| តើខ្ញុំមានសិទ្ធិអ្វីនៅពេលការិយាល័យ ជភស៊ ធ្វើការស៊ើបអង្កេតខ្ញុំ? | 8 |
| តើខ្ញុំមានសិទ្ធិអ្វី បើខ្ញុំមិនយល់ព្រមពីរបៀបដែលការិយាល័យ ជភស៊ ចាត់ចែងសំណុំរឿងរបស់ខ្ញុំ? | 9 |
| តើអ្វីជាការដាក់កុមារនៅក្រៅផ្ទះ? | 10 |
| តើ "បណ្ដឹងរកអាណាព្យាបាលភាពជាអ្វី? " | 11 |
| តើខ្ញុំជាឪពុកម្ដាយមានសិទ្ធិអ្វីនៅពេលកូនរបស់ខ្ញុំដាក់នៅថែរក្សាក្រៅផ្ទះឬសំរេចថាត្រូវការអាណាព្យាបាលភាព? | 11 |
| តើអ្វីខ្លះជាសិទ្ធិរបស់កូនខ្ញុំ? | 13 |
| តើគេរំពឹងសង្ឃឹមអ្វីពីខ្ញុំ? | 13 |
| តើខ្ញុំត្រូវយកកូនរបស់ខ្ញុំមកវិញរបៀបណា? | 14 |
| តើខ្ញុំត្រូវការមេធាវីណាម្នាក់ឬ? | 15 |
| តើខ្ញុំត្រូវមានផែនការសំរាប់អនាគតកូនរបស់ខ្ញុំរបៀបណា? | 16 |
| តើអ្វីជា "ការបញ្ឈប់នូវសិទ្ធិជាឪពុកម្ដាយ? | 17 |
| តើបុគ្គលមួយរូបៗអាចធ្វើអ្វីបាន បើមានការមិនយល់ព្រមជាមួយអ្នកធ្វើការ CPS ផ្នែកសង្គមកិច្ចអំពីសេចក្ដីសំរេចនៃសំណុំរឿង? | 18 |
| តើបុគ្គលមួយរូបៗអាចទទួលពត៌មានបន្ថែមទៀតនៅកន្លែងណា? | 18 |
| ច្បាប់ផ្ទៃក្នុងអំពីការមិនរើសអើង | 19 |

## តើកិច្ចបំរើផ្នែកការពារកុមារជាអ្វី(CPS)?

CPS ជាសកម្មភាពបំរើមួយរបស់បុគ្គលិកនៅក្នុងនាយកដ្ឋានផ្នែកបំរើកុមារនឹងគ្រួសារ (DCFS)
នៃក្រសួងសង្គមកិច្ចនឹងសុខាភិបាល(DSHS)។
CPS ទទួលខុសត្រូវការពារក្មេងពីការធ្វើទុក្ខទោស ឬធ្វេសប្រហែសមិនយកចិត្តទុកដាក់។

បុគ្គលិក CPS តម្រូវដោយច្បាប់ដើម្បីធ្វើការស៊ើបអង្កេត នៃរបាយការណ៍
ពីការមន្ទិលសង្ស័យទៅលើការធ្វើទុក្ខទោស ឬធ្វេសប្រហែសមិនយកចិត្តទុកដា
ក់ដែលមានន័យស្របច្បាប់ទៅលើការធ្វើទុក្ខទោស ឬការធ្វេសប្រហែសមិន
យកចិត្តទុកដាក់ដល់ក្មេង។

## តើអ្វីជាការធ្វើទុក្ខទោស ឬធ្វេសប្រហែសមិនយកចិត្តទុកដាក់ដល់កុមារ?

ការធ្វើទុក្ខទោស ឬធ្វេសប្រហែសមិនយកចិត្តទុកដាក់ដល់ក្មេងមានច្រើនប្រភេទណាស់ CA/N :

ការធ្វើទុក្ខទោសដល់រាងកាយរួមទាំងធ្វើឲ្យក្មេងមានរបួសដែលមិនមែនជាភាពគ្រោះថ្នាក់
(បាក់ឆ្អឹង ជាំ រលាក មុត ឬរបួសផ្សេងៗទៀត) ឬអំពើខ្លះដែលអាចធ្វើឲ្យមាន
ទុក្ខទោសយ៉ាងធ្ងន់ធ្ងរដល់ក្មេងប៉ុន្តែជាសំណាងល្អមិនមែន(វាយក្មេងដោយគ្រឿងអាវុធ
រាលកៃកាំភ្លើងនៅពេលដែលក្មេងនៅក្បែរ ឬអំពើស្រដៀងគ្នានេះ)។

ធ្វើទុក្ខទោសខាងផ្លូវចិត្តរួមទាំងធ្វើឲ្យក្មេងមានអារម្មណ៍ថា គាត់/នាង មិនបានស្រឡាញ់ចូលចិត្ត
ឬដែលធ្វើឲ្យគេមាន
អារម្មណ៍ជាមនុស្សអាក្រក់ ឬគ្មានតម្លៃ(ការបន្ទាបបន្ថោក
ឬការបង្ហាញក្មេងថាខុស មិនអនុញ្ញាតិឲ្យក្មេងមានមិត្តភក្តិ
ហៅឈ្មោះអាក្រក់ហើយអត្តចរិតនឹងស្រដៀងគ្នាដ៏ទៃទៀត)។
ឧប្បត្តិហេតុនៃអំពើរហិង្សានៅក្នុងគ្រួសារអាចចាត់ថា
ជាអំពើទុក្ខទោសខាងផ្លូវចិត្តដល់ក្មេងក៏មានដែរ។



ការធ្វេសប្រហែសមិនយកចិត្តទុកដាក់អ
ាចរួមបញ្ចូលដូចជាមិនផ្តល់ឲ្យក្មេងនូវសុវត្ថិភាព
តាមផ្ទះ ជាមួយចំណីអាហារ  សំលៀកបំពាក់ ឬការថែរក្សាផ្នែកពេទ្យ/ធ្មេញ ដូចជាការ
ទុកក្មេងតូចឲ្យនៅម្នាក់ឯង ឬអ្នកណាម្នាក់ដែលមិនអាចថែរក្សា គាត់/នាងបានបើកបរនៅ
ពេលស្រវឹងហើយមានក្មេងដែលគ្មានខ្សែក្រវ៉ាត់ត្រឹមត្រូវនៅក្នុងរថយន្តជាមួយ
ជាដើម។ ការមិនមើលត្រួតត្រាក្មេងជំទង់ក៏អាចសំរេចថាជាការ
ធ្វេសប្រហែសមិនយកចិត្តទុកដាក់ដែរ។

ការធ្វើទុក្ខទោសខាងផ្លូវភេទរួមទាំងការប្រើក្មេងសំរាប់អំពើខាងផ្លូវភេទ ថតរូបអាសអាភាសរបស់ក្មេង ធ្វើឲ្យក្មេងក្លាយជាស្រីពេស្យា ឬអំពើខាងផ្លូវភេទរបៀបផ្សេងទៀតជាមួយក្មេង។

មានអំពើរផ្សេងទៀតដែលអាចសំរេចថាជាប្រភេទធ្វើទុក្ខទោស នឹងធ្វេសប្រហែសមិនយកចិត្តទុកដាក់ដល់ក្មេង ហើយក្នុងករណីនិមួយៗគឺត្រូវតែសំរេចថាតើសុខភាពរបស់ក្មេងមានសន្តិសុខ ឬសុខមាលភាពក្មេងមានគ្រោះថ្នាក់ ឬធ្លាក់ក្នុងសភាពគ្រោះថ្នាក់។

## តើការិយាល័យ CPS ឮអំពីខ្ញុំដោយរបៀបណា?

CPS បានទទួលសេចក្តីរាយការណ៍ឲ្យយោបល់ថាកូនរបស់អ្នកមិនបានផ្តល់ការការពារ ឬថែរក្សាឲ្យដូចដែលពួកគេត្រូវការនោះទេ។

> “ជនណាម្នាក់ដែលធ្វើរបាយការណ៍ទៅ CPS អាចស្នើសុំឲ្យទុកឈ្មោះគេទុកជាសម្ងាត់។”

ជនខ្លះៗដូចជាវេជ្ជបណ្ឌិត គិលានុបដ្ឋាក-យិកា គ្រូបង្រៀន អ្នកបំរើឲ្យយោបល់ផ្នែកសង្គមកិច្ច អ្នកចិត្តវិជ្ជា ឱសថការី អ្នកផ្តល់ការថែរក្សាពេលថ្ងៃ មន្ត្រីផ្នែកដោះលែងនិតិថិជនមានលក្ខ័ណ្ឌនិយោជិត DSHS និយោជិកខាងក្រសួងកែលំអរ អ្នកធ្វើសពវិភាគ នឹងមនុស្សធំដែលរស់នៅជាមួយអ្នកធ្វើទុក្ខទោស ឬធ្វេសប្រហែសមិនយកចិត្តទុកដាក់ដល់ក្មេងគឺតម្រូវដោយច្បាប់ឲ្យរាយការណ៍នូវមន្ទិលសង្ស័យពីការធ្វើទុក្ខទោសឬធ្វេសប្រហែសមិនយកចិត្តទុកដាក់ទៅការិយាល័យ CPS ឬទៅប៉ូលិស (RCW 26.44.030)។

ជនណាផ្សេងទៀតក៏ដោយដែលជឿថាក្មេងនេះត្រូវគេធ្វើទុក្ខទោស ឬធ្វេសប្រហែសមិនយកចិត្តទុកដាក់ជននោះអាចសម្តែងការស្មោះត្រង់រាយការណ៍នូវឧប្បត្តិហេតុនេះទៅ DSHS ឬក៏ទៅប៉ូលិស។ របាយការណ៍ដោយការព្យាបាទ ឬក្លែងក្លាយខុសដោយចេតនាគឺជាបទល្មើសជាមជ្ឈិមហើយអាចយកមកកាត់ទោសតាមច្បាប់លេខ (RCW 26.44.060(4))។ ជនដែលត្រូវតែធ្វើរបាយការណ៍តម្រូវឲ្យធ្វើការបញ្ជូនរបាយការណ៍របស់គេក្នុងរវាង 48 ម៉ោងនៃពេលដែលពួកគេបានដឹងថាមានកើតឡើង។ ជនណាម្នាក់ដែលធ្វើរបាយការណ៍ទៅ CPS អាចស្នើសុំឲ្យទុកឈ្មោះគេជាសម្ងាត់។

## តើការិយាល័យ CPS មានសិទ្ធិអ្វីដើម្បីធ្វើសម្ភាសន៍កូនរបស់ខ្ញុំ?

ច្បាប់អនុញ្ញាតឲ្យ CPS ដើម្បីធ្វើការស៊ើបអង្កេតពីសេចក្តីរាយការណ៍ដែលមន្ទិលសង្ស័យថាក្មេងត្រូវគេធ្វើទុក្ខទោសឬធ្វេសប្រហែសមិនយកចិត្តទុកដាក់។

ដើម្បីធ្វើការស៊ើបអង្កេតឲ្យបានចប់សព្វគ្រប់បុគ្គលិកធ្វើការ CPS នឹងទៅពិភាក្សាជាមួយអ្នក នឹងជាមួយកូនរបស់អ្នកហើយនឹងជាមួយជនផ្សេងទៀតដែលប្រហែលមានពត៌មានសំខាន់ៗ។ CPS មានសិទ្ធិធ្វើសម្ភាសន៍កូនរបស់អ្នកមុននឹងប្រាប់អ្នកឲ្យដឹង ឬដោយមិនមានការអនុញ្ញាតពីអ្នកផង។ គេអាចធ្វើសម្ភាសន៍កូនក្មេងនៅសាលារៀន នៅកន្លែងថែរក្សា នៅតាមផ្ទះ ឬនៅកន្លែងណាដែលងាយស្រួលដល់ក្មេង។

បើកូនរបស់អ្នកបានធ្វើសម្ភាសន៍ដោយ CPS អ្នកនឹងត្រូវគេបញ្ជាក់ឲ្យដឹងយ៉ាងឆាប់រហ័ស។

CPS នឹង ប៉ូលីសមានអំណាចថតរូបរបស់ក្មេងសំរាប់ធ្វើសំណុំរឿងលក្ខណៈរាងកាយរបស់ក្មេងជាការចាំបាច់។

បន្ទាប់ពីធ្វើការស៊ើបអង្កេតដែលរួមទាំងការប៉ាន់ប្រមាណនៃកម្លាំងនឹងសភាពគ្រោះថ្នាក់នៃគ្រួសារដល់ក្មេង បុគ្គលិកធ្វើការផ្នែកសង្គមកិច្ចអាចបន្តធ្វើការទៅពិនិត្យនៅផ្ទះរបស់អ្នកដើម្បីពិភាក្សាពីបញ្ហាខ្លះដែលអ្នកមានជាមួយកូនរបស់អ្នកហើយប្រាប់នូវជំនួយដែលមានដើម្បីជួយដល់អ្នកក្នុងការធ្វើឲ្យប្រសើរឡើងចំពោះអ្នកនឹងគ្រួសាររបស់អ្នក។

## តើនៅពេលណាប៉ូលីសមានការជាប់ទាក់ទងជាមួយ?

របាយរាយការណ៍នៃការមន្ទិលសង្ស័យពីការធ្វើទុក្ខទោស ឬធ្វេសប្រហែសមិនយកចិត្តទុកដាក់នេះអាចបញ្ជូនទៅ CPS ឬទៅកន្លែងប៉ូលីសតាមស្រុក។ ប៉ូលីសតម្រូវឲ្យប្រាប់មក CPS ពីសេចក្តីរាយការណ៍ទាំងអស់ដែលគេបានទទួល។

បុគ្គលិក CPS តម្រូវឲ្យបញ្ជាក់ប្រាប់ ប៉ូលីសនូវសេចក្តីរាយការណ៍ទាំងអស់ដែលបង្ហាញពីការស្លាប់ របួសខាងរាងកាយ ការធ្វើទុក្ខទោសខាងផ្លូវភេទចំពោះក្មេងឬដែលបង្ហាញពីបទល្មើសដ៏ទៃទៀត។

> ប៉ូលីសអាចជាប់ទាក់ទងជាមួយបើការដាក់ក្មេងចូលទៅក្នុងកន្លែងការពារឃុំគ្រងវាជាការចាំបាច

ប៉ូលីសអាចជាប់ទាក់ទងជាមួយបើការដាក់ក្មេងចូលទៅក្នុងកន្លែងការពារឃុំគ្រងវាជាការចាំបាច់ ប៉ូលីសក៏អាចត្រូវគេសុំឲ្យជួយបានដែរបើមានមូលហេតុបារម្ភពីសន្តិសុខរបស់បុគ្គលិកធ្វើការ CPS ។

ទោះបីជាបុគ្គលិក CPS នឹងប៉ូលីសធ្វើការរួមគ្នាក៏ដោយពួកគេអាចធ្វើការស៊ើបអង្កេតដោយឡែកពីគ្នា។ ប៉ូលីសធ្វើការស៊ើបអង្កេតខាងបទឧក្រិដ្ឋ ហើយ CPS

ធ្វើការប៉ាន់ប្រមាណខាងគ្រួសារ។ ទោះបីជាឧក្រិដ្ឋកម្មមិនត្រូវបានចោទប្តឹងក៏ដោយ CPS អាចនៅតែមានការទាក់ទងជាមួយគ្រួសារនោះដែរ។

## តើការ "ការពារឃុំគ្រងជាអ្វី"?

នៅក្នុងសភាពការជាបន្ទាន់កន្លែងណាដែលបង្ហាញថាក្មេងស្ថិតនៅក្នុងសភាពមានគ្រោះថ្នាក់ភ្លាមៗ ឬការធ្វើទុក្ខទោស ធ្វេសប្រហែសមិនយកចិត្តទុកដាក់ដ៏ធ្ងន់ធ្ងរបានកើតមានរួចទៅហើយនោះ ភ្នាក់ងារប៉ូលីសអាចយកក្មេងនេះទៅដាក់ក្នុងកន្លែងការពារឃុំគ្រង" មិនលើសពី 72 ម៉ោងទេ(មិនរាប់ថ្ងៃ សៅរ៍ អាទិត្យ នឹងថ្ងៃបុណ្យទេ)។ បន្ទាប់ពីការឃុំគ្រងមកក្មេង ត្រូវបញ្ជូនទៅ CPS ដែលជាអ្នកដាក់ក្មេងនោះឲ្យនៅជាមួយសាច់ញាតិ ឬនៅផ្ទះមានអាជ្ញាប័ណ្ណដែលសំរាប់មើលចិញ្ចឹមក្មេង។



ការធ្វើសវនាការជាមួយតុលាការត្រូវធ្វើឡើងនៅក្នុងរយៈពេល 72 ម៉ោង (មិនរាប់ថ្ងៃ សៅរ៍ អាទិត្យនឹងថ្ងៃបុណ្យទេ) ពេលដែលដាក់ក្មេងនៅក្នុងកន្លែងឃុំគ្រង។

## តើវាយ៉ាងដូចម្តេចទៅវិញ នៅពេលគេដាក់កូនខ្ញុំឲ្យនៅក្នុងអាណាព្យាបាលការពារ?

នៅពេលគេដាក់កូនអ្នកឲ្យនៅក្នុងអាណាព្យាបាលការពារ,គេនឹងសរសេរសំបុត្រ ទៅជំរាបអ្នកឲ្យដឹងយ៉ាងឆាប់បំផុត ។ គេនឹងប្រគល់ក្រដាសមួយ ដែលប្រាប់ពីពេលវេលានិងមូលហេតុនៃការដាក់កូនរបស់អ្នក ឲ្យនៅក្នុងអាណាព្យាបាលការពារ ។ គេនឹងប្រាប់ឈ្មោះ, លេខទូរស័ព្ទរបសអ្នកធ្វើការបំរើ CPS និង/ឬការិយាល័យដែលអ្នកអាចរកពត៌មានបានច្រើនទៀត ។ គេនឹងជំរាបអ្នកឲ្យដឹងអំពីពេលវេលាហើយនិងទីកន្លែងសវនាការ នៃការទុកដាក់ឲ្យនៅក្នុងជំរកថែទាំ ហើយនិងវិធីដែលអ្នកអាចរកមេធាវីដែលគេតែងតាំង សំរាប់តុលាការ ។

បើសវនាការរបស់អ្នកកើតឡើងចំពោះមុខអធិការតុលាការអ្នកមានសិទ្ធិធ្វើឲ្យសេចក្តីសំរេចរបស់អធិការតុលាការពិនិត្យសាឡើងវិញដោយចៅក្រមខាងតុលាការជាន់ខ្ពស់។ ដើម្បីសុំធ្វើការពិនិត្យសាឡើងវិញនោះអ្នកត្រូវដាក់ញត្តិសំរាប់ការពិនិត្យសាឡើងវិញជាមួយតុលាការក្នុងរវាង 10 ថ្ងៃនៃការដាក់ជាផ្លូវការនៃសេចក្តីសំរេចរបស់អធិការតុលាការ។

DCFS អាចកំណត់ថាសកម្មភាពរបស់តុលាការគឺមិនចាំបាច់ទេទោះបីបន្ទាប់ពីការការពារឃុំគ្រងដែលធ្វើដោយប៉ូលីសក៏ដោយ។នៅក្នុងករណីនោះគេអាចសុំឲ្យអ្នកចុះហត្ថលេខាលើកិច្ចព្រមព្រៀងដាក់នៅតាមផ្ទះចិញ្ចឹមដោយស្ម័គ្រចិត្តជាឯកសារហូតទាល់តែបញ្ហាត្រូវបានដោះស្រាយរួច។ ឬកូនរបស់អ្នកអាចត្រឡប់មកក្នុងការបំរើនៅក្នុងផ្ទះរបស់អ្នកវិញ។

## តើកិច្ចបំរើអ្វីដែលអាចមានចំពោះខ្ញុំនឹងគ្រួសាររបស់ខ្ញុំ?

DSHS ផ្តល់ការបំរើជាច្រើនដើម្បីដោះស្រាយជាមួយនឹងបញ្ហាទាំងនេះ។ ការបំរើខ្លះគឺផ្តល់ដោយផ្ទាល់ពី DSHS ហើយផ្សេងទៀតគឺផ្តល់ឲ្យតាមរយ:សហគមន៍។ ការបំរើដោយ CPS មិនយកថ្លៃឈ្នួលហើយមិនគិតលើប្រាក់ចំណូលទេ។ ទោះជាយ៉ាងណាក៏ដោយ បើគ្រួសាររបស់អ្នកត្រូវបានបញ្ជូនទៅភ្នាក់ងារផ្សេងទៀតដែលគេទារថ្លៃឈ្នួល អ្នកប្រហែលជាតម្រូវឲ្យបង់ថ្លៃឈ្នួលនោះ។ ការបំរើក្រៅផ្ទះដូចជាការមើលថែរក្សាចិញ្ចឹមក្មេងមានថ្លៃឈ្នួលដែលអ្នកត្រូវតែបង់។

នេះគឺជាកិច្ចបំរើខ្លះៗដែលបុគ្គលិក CPS អាចមានលទ្ធភាពជួយគ្រួសាររបស់អ្នករកបាន: (មិនមែនគ្រប់ការបំរើដែលនៅក្នុងនេះអាចមានគ្រប់កន្លែងនោះទេ)

- ផ្ទះ/សំលៀកបំពាក់/ជំនួយខាងប្រាក់កាសដែលមានកំរិត
- ការបំរើផ្នែកសុខភាព/ការថែរក្សាផ្នែកពេទ្យ/ការថែរក្សាផ្នែកធ្មេញ
- ការបំរើឧបត្ថម្ភខាងផ្ទះសំបែង
- ថែទាំក្មេង
- បំរើផ្នែកការងារ
- ថ្នាក់បង្រៀនឪពុកម្តាយ
- ផែនការបំរើគ្រួសារ
- ការដឹកនាំ

> “ការបំរើដោយ CPS គឺមិនមានថ្លៃឈ្នួលហើយមិនគិតទៅលើប្រាក់ចំណូលទេ”

- ការបំរើផ្នែកជំងឺសតិ
- ការឲ្យឱវាទរវាងប្ដីប្រពន្ធនឹងគ្រួសារ
- កន្លែងចែកចំណីអាហារ (Food Bank)
- ការបំរើផ្នែកច្បាប់
- កម្មវិធីផ្នែកគ្រឿងញៀននឹងគ្រឿងស្រវឹង
- ជំនួយផ្នែកស្ម័គ្រចិត្ត ខាងឪពុកម្ដាយ ឪពុកម្ដាយអនាមិក
- អំពើហិង្សាក្នុងគ្រួសារ/កម្មវិធីផ្នែកវាយតប់ឬប៉ះពាល់ខាងផ្លូវភេទ

## តើប្រព័ន្ធឆ្លើយតបរបៀបផ្សេងទៀតជាអ្វី (ARS)?

នៅក្នុងរដ្ឋវ៉ាស៊ីនតោន របាយការណ៍របស់ CPS គឺត្រូវឲ្យតម្លៃដោយប្រើការប៉ាន់ប្រមាណខាងគ្រោះថ្នាក់ជាគំរូ។ បើពតិមានដែលឲ្យទៅបុគ្គលិកដែលទទួលនោះបង្ហាញថាកំរិតគ្រោះថ្នាក់របស់កូនអ្នកមានកំរិតទាប សំណុំរឿងរបស់អ្នកនឹងត្រូវគេបញ្ជូនទៅភ្នាក់ងារខាងក្រៅដែលគេចុះកុងត្រាជាមួយ CPS ផ្ដល់ការឧបត្ថម្ភពិសេសដើម្បីជួយអ្នកកសាងសភាពការជុំវិញខ្លួនរបស់អ្នកនឹងកូនរបស់អ្នកដែលមានការការពារពិតប្រាកដនិងដោយរំភើបចិត្តឬប្រភេទនៃការឧបត្ថម្ភចំពោះអ្នកផ្សេងៗទៀត។

ការចូលរួមចំណែកជាមួយអ្នកផ្ដល់ការបំរើ ARS គឺដោយស្ម័គ្រចិត្ត ហើយអ្នកអាចបដិសេធនូវការបំរើនេះ។ ទោះជាយ៉ាងណាក៏ដោយអ្នកផ្ដល់ការបំរើទាំងនេះតែងតែជួយអ្នកនឹងកូនរបស់អ្នកទទួលការបំរើដែលធ្វើឲ្យគេរីករាយនឹងងាយស្រួលជាទីបំផុត។ យើងជឿថា បើអ្នកមានប្រភេទនៃការឧបត្ថម្ភដែលអ្នកត្រូវការនៅក្នុងសហគមន៍ អ្នកនឹងមិនក្លាយជាអតិថិជនរបស់ CPS ទេ។

## តើខ្ញុំមានសិទ្ធិអ្វីនៅពេលការិយាល័យ CPS ធ្វើការស៊ើបអង្កេតខ្ញុំ?

នៅពេលណាដែលក្រសួងបញ្ចប់របាយការណ៍នៃការស៊ើបអង្កេតពីការធ្វើទុក្ខទោស
ឬធ្វេសប្រហែសមិនយកចិត្តទុកដាក់នៅក្រោមជំពូកលេខ 26.44 RCW
ក្រសួងត្រូវតែប្រាប់ដល់អ្នកចោទប្រកាន់ពីការប្រព្រឹត្តបទឧក្រិដ្ឋនោះឲ្យដឹងពីរបាយ
ការណ៍នឹងសេចក្តីសំរេចពីការស៊ើបអង្កេតរបស់ក្រសួង។ សេចក្តីជូនដំណឹងនេះ
គឺត្រូវផ្ញើដោយសំបុត្របញ្ជាក់ពិសេសទៅបុគ្គលដែលអាសយដ្ឋានដឹងចុងក្រោយ។

សេចក្តីសំរេចអាចមានបីយ៉ាង។ បានរកឃើញមានន័យថាអ្នកធ្វើការស៊ើបអ
ង្កេតបានរកឃើញពត៌មានគ្រប់គ្រាន់ដែលជឿថាវាកើតមានច្រើនជាង
អត់ដែលជាការធ្វើទុក្ខទោស ឬធ្វេសប្រហែសដែលបានចោទនោះគឺកើតឡើងមែន។
គ្មានមូលដ្ឋានមានន័យថាអ្នកធ្វើការស៊ើបអង្កេតបានរកឃើញពត៌មានថាកើតច្រើនជាង
អត់ថាការចោទប្រកាន់ពីការធ្វើទុក្ខទោស ឬធ្វេសប្រហែសមិនយកចិត្តទុក
ដាក់មិនមានកើតឡើង។ មិនដាច់ស្រេច មានន័យថាអ្នកធ្វើការស៊ើបអង្កេតមិនអា
ចធ្វើសេចក្តីសំរេចថាតើការធ្វើទុក្ខទោស ឬធ្វេសប្រហែសមិនយកចិត្តទុកដា
ក់មានកើតឡើងយ៉ាងណាទេ។

បើអ្នកត្រូវគេដាក់ឈ្មោះនៅក្នុងរបាយការណ៍ថាបានរកឃើញពីការធ្វើទុក្ខទោស
ឬធ្វេសប្រហែសមិនយកចិត្តទុកដាក់ អ្នកមានសិទ្ធិធ្វើការពិនិត្យសាឡើងវិញនឹង
ធ្វើការកែប្រែពីច្បាប់នៃសេចក្តីសំរេចនោះ ក្នុងរវាងម្ភៃថ្ងៃនៃប្រក្រតិទិនបន្ទាប់
ពីបានទទួលសេចក្តីបញ្ជាក់ជាលាយលក្ខអក្សរពីក្រសួង អ្នកអាចធ្វើសេចក្តីស្នើសុំ
ឲ្យក្រសួងពិនិត្យសាឡើងវិញនៃសេចក្តីសំរេចនេះ។ ការស្នើសុំត្រូវតែធ្វើជាលា
យលក្ខអក្សរ។ បើការស្នើសុំរបស់អ្នកសំរាប់ពិនិត្យសាឡើងវិញមិនធ្វើ
ក្នុងរយៈពេលដែលតម្រូវទេនោះ អ្នកមិនអាចធ្វើការជំទាស់តវ៉ាពីសេចក្តីសំរេចនេះ
តទៅមុខបានទៀតទេហើយអ្នកមិនមានសិទ្ធិសុំធ្វើការវិនិច្ឆ័យខាងសវនាការ
ឬពិនិត្យសាឡើងវិញពីតុលាការនៃសេចក្តីសំរេចនេះ។

ពេលបានទទួលបង្កាន់ដៃនៃសេចក្តីស្នើសុំជាលាយលក្ខអក្សរសំរាប់ពិនិត្យសាឡើងវិញ
ក្រសួងនឹងធ្វើការពិនិត្យសាឡើងវិញ ហើយបើវាសមរម្យគេនិងប្តូរសេចក្តីសំរេចនេះ។
បុគ្គលិកនៃអ្នកចាត់ចែងតំបន់ត្រូវទទួលខុសត្រូវការពិនិត្យសាឡើងវិញ។
នៅពេលបញ្ចប់ការពិនិត្យសាឡើងវិញ ក្រសួងនឹងជំរាប់អ្នកឲ្យដឹងជាលាយលក្ខអ
ក្សរពីសេចក្តីសំរេចចិត្តរបស់ទីភ្នាកងារ។ លិខិតជូនដំណឹងនេះនឹងផ្ញើជូនទៅអ្នក
ដោយសំបុត្របញ្ជាក់ពិសេសទៅអាសយដ្ឋានដែលដឹងចុងក្រោយរបស់អ្នក។

បើធ្វើតាមការពិនិត្យសាឡើងវិញរបស់ទីភ្នាក់ងារ របាយការណ៍នៅតែមានលក្ខណបានរកឃើញ អ្នកអាចស្នើសុំធ្វើសវនាការវិនិច្ឆ័យដើម្បីតវ៉ាពីសេចក្ដីសំរេចនេះ។ ការស្នើសុំសំរាប់សវនាការវិនិច្ឆ័យត្រូវតែដាក់ប្ដឹងក្នុងរវាងសាមសិបថ្ងៃបន្ទាប់ពីបានទទួលលិខិតនៃការកំណត់ពិនិត្យសាឡើងវិញរបស់ទីភ្នាក់ងារ។ បើការស្នើសុំរបស់អ្នកសំរាប់ពិនិត្យសាឡើងវិញមិនធ្វើក្នុងរយៈពេលដែលតម្រូវទេនោះ អ្នកមិនអាចធ្វើការជំទាស់តវ៉ាពីសេចក្ដីសំរេចនេះតទៅមុខបានទៀតទេហើយអ្នកមិនមានសិទ្ធិធ្វើការវិនិច្ឆ័យខាងសវនាការ ឬពិនិត្យសាឡើងវិញពីតុលាការនៃសេចក្ដីសំរេចនេះ។

## តើខ្ញុំមានសិទ្ធអ្វីបើខ្ញុំមិនយល់ព្រមពីរបៀបដែលការិយាល័យ CPS ចាត់ចែងសំណុំរឿងរបស់ខ្ញុំ?

ការចាប់អារម្មណ៍ជាចំបង់របស់ ជភស៊ី គឺធានាអះអាងថាគ្រប់ជនទាំងអស់ដែលទាក់ទងជាមួយទីភ្នាក់ងារនេះយកចិត្តទុកដាក់ឲ្យស្មើភាពគ្នានឹងដោយគោរព។ ដោយមូលហេតុនេះ យើងមានច្បាប់ផ្ទៃក្នុងនៃការតវ៉ារបស់ពលរដ្ឋនឹងទម្រង់ការហើយនឹងកូនសៀវភៅតូចពិសេសដែលចែងអំពីរបៀបធានាអះអាងពីការចាប់អារម្មណ៍បានលើកឡើងតាមសណ្ដាប់ធ្នាប់ត្រឹមត្រូវតាមរបៀបរបបពេលវេលា។ ការចាប់អារម្មណ៍ពីរបៀបដែលចាត់ចែងសំណុំរឿងរបស់អ្នកអាចនាំសួរដោយកូនរបស់អ្នកដោយសមាជិកគ្រួសាររបស់អ្នក ដោយអ្នកឯកទេសនៅក្នុងសមាគមន៍ ឬដោយអ្នកណាម្នាក់ដែលមានចំណេះវិជ្ជាដឹងពីសភាពការនេះ។

បើអ្នកមានការតវ៉ា ឬចាប់អារម្មណ៍ពីសំណុំរឿងរបស់អ្នកបានចាត់ចែងឬកំពុងតែចាត់ចែងដោយ CPS ជាដំបូងអ្នកគួរប្រាប់នូវការចាប់អារម្មណ៍របស់អ្នកទៅបុគ្គលិកធ្វើការផ្នែកសង្គមកិច្ចរបស់អ្នក។ បើបញ្ហានេះមិនបានដោះស្រាយអ្នកអាចទាក់ទងទៅអ្នកត្រួតត្រាអ្នកធ្វើការតែម្ដង។ បើរឿងនេះនៅតែមិនអាចដោះស្រាយដោយអ្នកត្រួតត្រាអ្នកអាចទាក់ទងទៅទីកន្លែងអភិបាលកិច្ចហើយបន្ទាប់ពីនោះមក ទៅអភិបាលកិច្ចតំបន់។ អ្នកអាចទាក់ទងទៅ ការិយាល័យផ្នែកទំនាក់ទំនងតាមលេខទូរសព្ទ 1-800-723-4831 សំរាប់ជំនួយខាងដោះស្រាយបញ្ហាគ្រប់ពេល។

ជនមួយរូបៗធ្វើការតវ៉ាទៅការិយាល័យស៊ើបអង្កេតពាក្យបណ្តឹងខាងគ្រួសារនឹងកុមារតាមលេខទូរសព្ទ 1-800-571-7321 ដែលជាទីភ្នាក់ងារដោយឡែកពី DSHS ហើយមានអំណាចស៊ើបអង្កេតពីការចាប់អារម្មណ៍ខ្លះអំពីសកម្មភាពរបស់អភិបាលកិច្ចកុមារដែលលើកឡើងដោយពលរដ្ឋណាម្នាក់នៅរដ្ឋវ៉ាស៊ីនតោន។ ការិយាល័យស៊ើបអង្កេតពាក្យបណ្តឹងតែងតែសង្ឃឹមថាទម្រង់ការដំណោះស្រាយការត្អូញត្អែរផ្ទៃក្នុងត្រូវប្រើមុនពេលដែលការិយាល័យបានទាក់ទងជាមួយ។

## តើអ្វីជាការដាក់កុមារនៅក្រៅផ្ទះ?

ភាគច្រើនពេលក្មេងរាយការណ៍ទៅ ជភស៊ គេមិនបានយកក្មេងនោះចេញពីផ្ទះរបស់គេទេ។ ក្មេងត្រូវគេដាក់ឲ្យឆ្ងាយពីឪពុកម្តាយរបស់គេតែនៅពេលជាចាំបាច់ដើម្បីការពារពួកគេពីអំពើទុក្ខទោសដែលកើតឡើង  ភ្លាមៗ ឬបន្តធ្វើទុក្ខទោស ឬធ្វេសប្រហែសមិនយកចិត្តទុកដាក់ប៉ុណ្ណោះ។

ធម្មតាបងប្អូនសាច់ញាតិដែលសមរម្យគឺជាអ្នកត្រូវបញ្ជូនក្មេងឲ្យទៅនៅ។ បើមិនមានបងប្អូនសាច់ញាតិសមរម្យ  ទេ ក្មេងនឹងត្រូវយកទៅដាក់នៅផ្ទះមើលថែរក្សាចិញ្ចឹមក្មេងដែលមានអាជ្ញាប័ណ្ណ។ ឪពុកម្តាយចិញ្ចឹមត្រូវផ្តល់ការ

ថែរក្សាពីមួយថ្ងៃទៅមួយថ្ងៃសំរាប់ក្មេងហើយទទួលប្រាក់ខែដែលបង់សងមកវិញដើម្បីជួយគ្រប់គ្រងថ្ងៃថែទាំចំពោះក្មេងនោះ។ កូនក្មេងនឹងឪពុកម្តាយចិញ្ចឹមត្រូវត្រួតត្រាដោយអ្នកធ្វើការផ្នែកសង្គមកិច្ចដែលចាត់តាំងរហូតដល់ក្មេងនោះនៅតែដាក់ក្នុងកន្លែងចិញ្ចឹមនេះ។

កូនក្មេងខ្លះមានបញ្ហាធ្ងន់ធ្ងរណាស់ដែលវាមិនអាចស្នាក់នៅក្នុងសភាពការជាគ្រួសារបាន។ កូនក្មេងទាំងនេះគឺត្រូវដាក់នៅក្នុងផ្ទះជាក្រុម ឬនៅក្នុងមន្ទីរថែរក្សាព្យាបាលដូចជាការបំរើដែលមានឧបករណ៍ដ៏ប្រសើរដើម្បីដោះស្រាយជាមួយកូនក្មេងដែលធ្វើអំពើចរិយាខាងក្រៅសាហាវឃោឃៅ ឬដែលមានបញ្ហាសុខភាពខាងសតិអារម្មណ៍។

> “កូនក្មេងខ្លះគឺមានបញ្ហាដ៏ធ្ងន់ធ្ងរដែលវាមិនអាចស្នាក់នៅក្នុងសភាពការជាគ្រួសារបាន”

## តើ "បណ្ដឹងរកអាណាព្យាបាលភាពជ

ក្នុងករណីដែលមានសភាពធ្ងន់ធ្ងរ ក្រសួង ឬជនដ៏ទៃទៀតអាចដាក់ពាក្យបណ្ដឹងជាមួយតុលាការដោយបញ្ជាក់ថាកុមារ :

- បានត្រូវគេបំបោះបង់ចោល
- បានត្រូវគេធ្វើទុក្ខទោស ឬធ្វេសប្រហែសមិនយកចិត្តទុកដាក់
- គ្មានឪពុកម្ដាយ អ្នកអាណាព្យាបាល អ្នកគ្រប់គ្រងដែលមានសមត្ថភាពថែទាំចំពោះក្មេងនោះ។

តុលាការនឹងធ្វើសវនាការដើម្បីសំរេចថាតើមូលហេតុណាមួយនៃមូលហេតុទាំងនេះសំរាប់ការរកអាណាព្យាបាលភាពមាន ឬទេ។ តុលាការអាចសំរេចថាតើកូនក្មេងគួរតែនៅក្នុងផ្ទះរបស់គាត់/នាងដោយខ្លួនឯង ឬក៏ដាក់នៅផ្ទះក្រៅ ហើយអ្នកណាជាអ្នកត្រួតត្រាក្មេងនៅពេលដែលកំពុងមានការទាក់ទងជាមួយតុលាការ។ ដីកាបញ្ជាបណ្ដោះអាសន្នពីតុលាការនេះហៅថា "ការរកអាណាព្យាបាលភាព"



សវនាការពិនិត្យសាឡើងវិញនៃការរកអាណាព្យាវលភាពគឺត្រូវធ្វើឡើងរាល់ពេលប្រាំមួយខែដើម្បីឲ្យឃើញថាតើផែនការរបស់តុលាការធ្វើការបង្រួបបង្រួមគ្រួសារមានភាពជឿនលឿនឬយ៉ាងណាហើយតើការទាក់ទងជាមួយតុលាការត្រូវការបន្ត ឬមិនបន្ត។

## តើខ្ញុំជាឪពុកម្ដាយមានសិទ្ធិអ្វីនៅពេលកូនរបស់ខ្ញុំដាក់នៅថែរក្សាក្រៅផ្ទះ ឬសំរេចថាត្រូវការអាណាព្យាបាលភាព?

ឪពុកម្ដាយមានសិទ្ធិបន្ថែមទៀតលុះត្រាតែតុលាការចេញបញ្ជាផ្សេងវិញ។ បើកូនរបស់អ្នកដាក់នៅកន្លែងការពារគ្រប់គ្រងអ្នកមានសិទ្ធិត្រូវគេប្រាប់ដំណឹងឲ្យទាន់តាមពេលវេលាហើយបញ្ជាក់ថាមូលហេតុអ្វីបានជាក្មេងនេះត្រូវដាក់កន្លែងហ្នឹង។

បើកូនរបស់អ្នកត្រូវគេដាក់នៅក្រៅផ្ទះ (កន្លែងថែទាំក្មេងចិញ្ចឹម ផ្ទះចិញ្ចឹមជាក្រុម ឬមន្ទីរផ្សេងៗ) អ្នកមានសិទ្ធិទៅពិនិត្យសួរសុខទុក្ខជាមួយក្មេងនោះបើមិនដូច្នោះទេលើកលែងតែមានដីកាបញ្ជាពីតុលាការ។ ដីកាបញ្ជាពីតុលាការជាធម្មតាកំណត់លើភាពញឹកញាប់នឹងទីកន្លែងនៃការទៅពិនិត្យមើលនេះ។

អ្នកអាចសួរសំនួរពីសេចក្តីសំរេចចិត្តអ្វីមួយដែលដាក់កំរិត ឬបដិសេធពីសិទ្ធិនៃការទៅពិនិត្យសួរសុខទុក្ខនេះ។

CPS នឹងធ្វើអ្វីទាំងអស់ក្នុងអំណាចរបស់គេដើម្បីប្រាប់ឲ្យអ្នកដឹងពីការរីកចំរើននៃសុខភាព ការរីកចំរើនល្អូត លាស់នៅសាលារៀន ហើយនឹងចរិយាមាយាទរបស់កូនអ្នក។ ដើម្បីធ្វើកិច្ចការនេះឲ្យកើតឡើងបានអ្នកត្រូវឲ្យ បុគ្គលិកធ្វើការ CPS ដឹងពីការរៀបចំការរស់នៅរបស់អ្នក។

អ្នកមានសិទ្ធិដឹងនូវអ្វីដែលជាការរំពឹងសង្ឃឹមដើម្បីធ្វើឲ្យកូនរបស់អ្នកត្រូវបញ្ជូនត្រឡប់មក ផ្ទះវិញបន្ទាប់ពីស្នាក់នៅកន្លែងក្រៅផ្ទះ។

អ្នកមានសិទ្ធិធ្វើការសុំយោបល់នៅពេលមានការផ្លាស់ប្តូរត្រូវបានយកមកគិតគូរនៅក្នុងផែនការនៃសំណុំរឿងដែលប៉ះទង្គិចដល់អ្នកនឹងកូនរបស់អ្នក។

អ្នកមានសិទ្ធិទទួលជំនួយហើយ/ឬការឲ្យឱវាទសំរាប់បញ្ហាដែលត្រូវការដោះស្រាយ។

> អ្នកមានសិទ្ធិទទួលជំនួយហើយ/ឬការឲ្យឱវាទសំរាប់បញ្ហាដែលត្រូវការដោះស្រាយ ។

អ្នកមានសិទ្ធិទទួលលិខិតជូនដំណឹងជាមុនអំពីការចូលរួមនៅក្នុងសវនាការតុលាការអ្វីមួយដែលបានធ្វើស្តីពីកូនរបស់អ្នក ឬការប៉ះទង្គិចលើសិទ្ធិជាឪពុកម្តាយ (លើកលែងតែតុលាការធ្វើសកម្មភាពជាបន្ទាន់អាសន្ន)។

អ្នកមានសិទ្ធិស្នើសុំតុលាការធ្វើសវនាការថែរក្សាតាមទីជម្រកនៅពេលអ្នកមិនអាច (ដោយមានមូលហេតុល្អ) ដើម្បីចូលរួមសវនាការក្នុងកំឡុង 72 ម៉ោងនោះ។

អ្នកមានសិទ្ធិទទួលសេចក្តីសំរេចចិត្តសំរាប់សវនាការនិមួយៗដែលយោលទៅលើតែភស្តុតាងបានបង្ហាញនៅពេលធ្វើសវនាការជាមួយអបុរេនិច្ឆ័យចៅក្រម ឬការរកឃើញដោយអង្គហេតុពិត។

អ្នកមានសិទ្ធិរកមេធាវីពេលណាត់ដោយដែលមានទម្រង់ការទាក់ទងតជាមួយតុលាការ។ បើអ្នកមិនអាចជួលមេធាវីបានទេ អ្នកធ្វើការ CPS របស់អ្នកនឹងផ្តល់ពត៌មានពីរបៀបទទួលមេធាវីម្នាក់ដែលចាត់តាំងដោយតុលាការ។

អតិថិជនទាំងអស់មានសិទ្ធិទទួលការបំរើក្នុងភាសាដែលគេចូលចិត្តនៅក្នុងរបៀបវប្បធម៌។

## តើអ្វីខ្លះជាសិទ្ធិកូនរបស់ខ្ញុំ?

**កូនរបស់អ្នកមានសិទ្ធិដែរ រួមទាំង:**

- សិទ្ធិទទួលចំណីអាហារ ទីជម្រក នឹងសំលៀកបំពាក់ដើម្បីឲ្យជួបនូវសេចក្តីត្រូវការរបស់គាត់/នាង។
- សិទ្ធិការពារនឹងសេរីភាពអំពីការធ្វើទុក្ខទោស ការរុកគួន គ្រោះថ្នាក់ របួស និងធ្វេសប្រហែសមិនយកចិត្តទុកដាក់។
- សិទ្ធិផ្នែកសន្តិសុខផ្លូវចិត្ត
- សិទ្ធិទទួលព្យាបាលសុខភាព ដែលរួមទាំងរោគវិនិច្ឆ័យ ការព្យាបាលផ្នែកពេទ្យ ផ្នែកធ្មេញនឹងលក្ខណៈផ្នែកចិត្ត។
- សិទ្ធិការពារនូវសិទ្ធិរបស់ គាត់/នាង ក្នុងកំឡុងពេលតុលាការធ្វើដំណើរការ។ ជនមួយរូបហៅថា (អាណាព្យាបាលអនិតិជន) អាចចាត់តាំងដោយតុលាការដើម្បីការពារសិទ្ធិរបស់ក្មេង។ រឿងនេះកើតឡើងបើសកម្មភាពរបស់តុលាការអ្វីមួយកើតឡើង។

## តើគេរំពឹងសង្ឃឹមអ្វីពីខ្ញុំ?

**អ្នកមានការទទួលខុសត្រូវមួយចំនួន :**

- ដើម្បីផ្តល់ដល់កូនរបស់អ្នកនូវសំលៀកបំពាក់ជាចាំបាច់នឹងរបស់ផ្ទាល់ខ្លួន (អាវដេក ប្រដាប់លេងឬរបស់ផ្សេងទៀតដើម្បីជួយកូនរបស់អ្នកឲ្យបានសុខស្រួលថែមទៀតបើគាត់/នាងនៅក្នុងការថែទាំក្រៅផ្ទះរបស់អ្នក។

- ទៅពិនិត្យសួរសុខទុក្ខកូនរបស់អ្នកជាធម្មតាតាមពេលនឹងកន្លែងយល់ព្រមជាមួយបុគ្គលិកធ្វើការ CPS បើអ្នកត្រូវរកមានការទៅពិនិត្យមើលរបស់អ្នកនោះជាការទទួលខុសត្រូវរបស់អ្នកក្នុងការប្រាប់ដំណឹងទៅអ្នក ធ្វើការ CPS ជាមុន។
- ធ្វើការជាមួយបុគ្គលិក CPS ក្នុងការរៀបចំផែនការពីអនាគតរបស់កូនអ្នករួមទាំងសកម្មភាពដែលអ្នកត្រូវការធ្វើ។
- ធ្វើការឆ្ពោះទៅរកការដោះស្រាយបញ្ហាដែលបណ្តាលឲ្យមានការធ្វើទុក្ខទោស ឬធ្វេសប្រហែសមិនយកចិត្តទុកដាក់។ បើបុគ្គលិកធ្វើការ CPS ហើយ/ឬ ក៏តុលាការបញ្ជូនអ្នកទៅកន្លែងណាផ្សេងដើម្បីទទួលជំនួយសំរាប់បញ្ហានេះ អ្នកគួរតែធ្វើតាមការបញ្ជូននោះ ឬពិភាក្សាជាមួយអ្នកធ្វើការផ្នែកសង្គមកិច្ចអំពីការចាប់អារម្មណ៍របស់អ្នក។
- ប្រាប់ដំណឹង ឬបញ្ជាក់អ្នកធ្វើការផ្នែកសង្គមកិច្ចឲ្យដឹងពីការផ្លាស់ប្តូរនៅក្នុងការរស់នៅរបស់អ្នក ដូចជាមានអាសយដ្ឋានថ្មី ឬលេខទូរសព្ទ ផ្លាស់ប្តូរលក្ខណ:ការងារ រៀបការ/លែងលះ ឬការផ្លាស់ប្តូរផ្សេងទៀតដែលប៉ះទង្គិចពីផែនការសំរាប់កូនរបស់អ្នក។
- ត្រូវរក្សាទុកការណាត់ជួបជាមួយបុគ្គលិកធ្វើការ CPS នឹងការជួយពីអ្នកវិជ្ជាជីវ:ដ៏ទៃទៀត។ បើអ្នកមិនអាចរក្សាការណាត់ជួប ឬត្រូវផ្អាក អ្នកត្រូវឲ្យអ្នកធ្វើការដឹងជាមុន។
- ដើម្បីផ្តល់ពត៌មានពីកូនរបស់អ្នក រួមទាំងការថែរក្សាផ្នែកពេទ្យពីមុន ពីឋាន:សិក្សា ឬពត៌មានផ្សេងទៀតដែលអាចប៉ះទង្គិចពីផែនការរបស់ក្មេង។
- ធ្វើការពិភាក្សាជាមួយបុគ្គលិកធ្វើការ CPS អំពីការថែរក្សានឹងការជឿនលឿនរបស់កូនអ្នក។
- ចេញថ្លៃឈ្នួលសំរាប់ការផ្តល់ថែរក្សាកូនរបស់អ្នក។

> “CPS ចង់រក្សាទុកកូនរបស់អ្នកនៅផ្ទះដ៏រាបណាវាមានសន្តិសុខដល់ក្មេង។”

## តើខ្ញុំត្រូវយកកូនរបស់ខ្ញុំមកវិញរបៀបណា?

CPS ចង់រក្សាទុកកូនរបស់អ្នកនៅផ្ទះដ៏រាបណាវាមានសន្តិសុខដល់ក្មេង។ CPS យកគាត់/នាងទៅដាក់នៅផ្ទះក្រៅពីព្រោះតែសភាពការនៅផ្ទះអ្នកបង្កើតភាពធ្វើឲ្យមានគ្រោះថ្នាក់ធ្វើឲ្យកូនរបស់អ្នកស្ថិតក្នុងភាពមានគ្រោះថ្នាក់ភ្លាមៗ។ ពាក្យបណ្តឹងអំពីអាណាព្យាបាលដែលអ្នកបានទទួលមួយច្បាប់នោះពិពណ៌នាពីលក្ខណ:ដែលបុគ្គលិកធ្វើការផ្នែកសង្គមកិច្ចបានគិតថាដាក់កូនរបស់អ្នកនៅក្នុងសភាពគ្រោះថ្នាក់។ បើអ្នកមិនយល់ពីអ្វីដែលនិយាយនៅក្នុងក្រដាសនោះទេ សួរអ្នកធ្វើការនឹងមេធាវីដើម្បីឲ្យគេពន្យល់ពីពាក្យបណ្តឹងនោះចំពោះអ្នក។ ដើម្បីឲ្យកូនរបស់អ្នកបានត្រឡប់សន្តិសុខដល់ក្មេង។មកអ្នកវិញលក្ខណ: ដែលពិពណ៌នានៅក្នុងពាក្យបណ្តឹងត្រូវតែដោះស្រាយ។

**របៀបដ៏ប្រសើរក្នុងការសំរេចនេះគឺ:**

- ត្រូវបង្ហាញខ្លួននៅតុលាការរាល់ពេលធ្វើសវនាការពីកូនរបស់អ្នក។ បើអ្នកមិនទៅចូលរួមសវនាការនេះទេ ចៅក្រមអាចបកស្រាយថាការមិនបង្ហាញខ្លួនរបស់អ្នកមានន័យថាអ្នកមិនខ្វាយខ្វល់ពីអ្វីដែលកើតឡើងចំពោះកូនរបស់អ្នកទេ។

- ត្រូវគោរពដីកាបញ្ជាតុលាការ។ ដីកាបញ្ជាណាដែលចេញដោយតុលាការចំពោះកូនរបស់អ្នកនឹងរួមបញ្ចូលពីផែនការសំណុំរឿងជាមួយសេចក្តីតម្រូវពិសេសសំរាប់អ្នក។ បើតុលាការចេញដីកាបញ្ជាឲ្យអ្នកចូលរួមថ្នាក់សំរាប់ចាត់ចែងកំហឹង ឬការព្យាបាលសារធាតុញៀន ចូរធ្វើទៅ សូម្បីបើអ្នកគិតថាអ្នកមិនត្រូវការក៏ដោយ។ អ្នកប្រហែលមានការភ្ញាក់ផ្អើលនូវអ្វីដែលអ្នកបានរៀនសូត្រអំពីខ្លួនអ្នកនៅក្នុងថ្នាក់ ឬការព្យាបាលនេះ។

- ធ្វើឲ្យមានសន្តិសុខដល់កូនរបស់អ្នកពេលត្រឡប់មកផ្ទះវិញ។ នេះគឺមានន័យថាសុំឲ្យអ្នកណាម្នាក់ផ្សេងទៀតចាកចេញពីផ្ទះរបស់អ្នក។ឬវាមានន័យថាដោះស្រាយនូវបញ្ហាដែលអ្នកមាន។ ឬវាមានន័យថាចាត់វិធានការទៅរកការរីកចំរើននៃលក្ខណ: រស់នៅក្នុងផ្ទះរបស់អ្នក។តុលាការនឹងមិនអនុញ្ញាតិឲ្យកូនរបស់អ្នកត្រឡប់មកផ្ទះវិញលុះត្រាតែមានការធានានូវសន្តិសុខត្រូវធ្វើដូច្នោះ។

## តើខ្ញុំត្រូវការមេធាវីណាម្នាក់ឬ?

អ្នកមានសេរីភាពបន្តទុកមេធាវីនៅគ្រប់ពេលបើអ្នកចង់។ ទោះជាយ៉ាងណាក៏ដោយអ្នកមិនអាចទទួលមេធាវីដែលចាត់តាំងដោយតុលាការ លើកលែងតែពាក្យបណ្តឹងរកអាណាព្យាបាលបានដាក់ប្តឹង។

បើពាក្យបណ្តឹងរកអាណាព្យាបាលបានដាក់ប្តឹង អ្នកត្រូវការមេធាវី ហើយបើអ្នកមិនមានសមត្ថភាពជួល តុលាការនឹងចាត់តាំងម្នាក់សំរាប់អ្នក។ បើកូនរបស់អ្នកត្រូវគេដាក់នៅកន្លែងការពារគ្រប់គ្រង លិខិតដែលអ្នកបានទទួលជាលាយល័ក្ខអក្សរនឹងប្រាប់អ្នកពីរបៀបសុំម្នាក់។ បើអ្នកមិនយល់សូមទាក់ទងអ្នកធ្វើការ CPS ឬតុលាការអនិតិជន។

មេធាវីរបស់អ្នកធ្វើជាតំណាងរកផលប្រយោជន៍អ្នកនៅតុលាការ។ ចូរចាំឲ្យច្បាស់អ្នកត្រូវពិភាក្សាជាមួយមេធាវីរបស់អ្នកមុនពេលធ្វើសវនាការនិមួយៗដើម្បីឲ្យគាត់/នាងធ្វើតំណាងអ្នកបានល្អប្រសើរ។ បើអ្នកនឹងឪពុកម្តាយដ៏ទៃកូនរបស់អ្នកដែលមិនរៀបការ ឬរស់នៅបែកគ្នាមេធាវីផ្សេងគ្នាអាចចាត់តាំងគឺសំរាប់អ្នកទាំងពីរដោយឡែកពីគ្នា។

កូនរបស់អ្នកប្រហែលជាមាន"(អាណាព្យាបាលអនិតិជន)" ចាត់តាំងជាតំណាងផលប្រយោជន៍ដ៏ប្រសើរចំពោះក្មេង។បុគ្គលនេះអាចចង់ពិភាក្សាជាមួយអ្នក។ បើដូច្នោះគាត់/នាងនឹងអាចជាតំណាងដ៏ប្រសើរសំរាប់កូនរបស់អ្នក បើអ្នកធ្វើរបាយការណ៍ពីអ្វីដែលអ្នកដឹងអំពីកូនរបស់អ្នក។



អ្នកធ្វើការ CPS របស់អ្នកក៏នឹងតំណាងដោយមេធាវីដែលផ្តល់ដោយការិយាល័យអគ្គមេធាវី។

## តើខ្ញុំត្រូវមានផែនការសំរាប់អនាគតកូនរបស់ខ្ញុំរបៀបណា?

ការមានផ្ទះនៅជាអចិន្ត្រៃគឺជាការសំខាន់ណាស់ចំពោះកូនក្មេង។ បើអ្នករស់នៅក្នុងផ្ទះមើលចិញ្ចឹមក្មេង ឬផ្លាស់ពីសាច់ញាតិមួយទៅសាច់ញាតិមួយកាលពីក្មេងអ្នកអាចយល់ថាជាការសំខាន់យ៉ាងណាចំពោះកូនរបស់អ្នក។

CPS ក៏យល់អញ្ចឹងដែរថាភាពអចិន្ត្រៃវាសំខាន់យ៉ាងណាចំពោះក្មេង។ ការដកយកក្មេងចេញពីគ្រួសាររបស់គាត់/នាង ធម្មតាជាការបណ្តោះអាសន្នទេ។ គោលដៅរបស់ CPS គឺត្រូវបញ្ចប់កន្លែងដាក់ក្មេងបណ្តោះអាសន្នហើយជួយធានានូវភាពប្រាកដប្រជាថាក្មេងមានសន្តិសុខនៅក្នុងផ្ទះរបស់គាត់/នាងខ្លួនឯង។

អ្នកអាចជួយកូនរបស់អ្នកដោយធ្វើការជាមួយ CPS បង្កើត ហើយសរសេរជាផែនការមួយ។ ផែនការនេះគួរតែចុះពីបញ្ហាដែលអ្នកនឹង CPS បានពិភាក្សា។ ផែនការគួរតែនិយាយពីអ្វីដែលត្រូវធ្វើដើម្បីកែតម្រូវនូវបញ្ហា អ្នកណានឹងត្រូវធ្វើអ្វី ហើយតើនឹងអស់រយៈពេលប៉ុន្មាន។

> “ការបញ្ឈប់នូវសិទ្ធិរបស់ឪពុកម្តាយមានន័យថាឪពុកម្តាយមិនមានសិទ្ធិ ឬការទទួលខុសត្រូវចំពោះក្មេងតទៅទៀតទេ។”

### តើអ្វីជា "ការបញ្ឈប់នូវសិទ្ធិជាឪពុកម្តាយ?

ការបញ្ឈប់នូវសិទ្ធិរបស់ឪពុកម្តាយមានន័យថាឪពុកម្តាយមិនមានសិទ្ធិ ឬការទទួលខុសត្រូវចំពោះក្មេងតទៅទៀតទេ។ឪពុកម្តាយនឹងមិនមានសិទ្ធិស្របច្បាប់ដើម្បីទៅជួប ឬទៅមើលក្មេង មិនមានសិទ្ធិគ្រប់គ្រងក្មេង មិនមានសិទ្ធិសំរេចពីអនាគតរបស់ក្មេងទេ។ តុលាការមានអំណាចធ្វើសេចក្តីសំរេចបញ្ចប់ពីសិទ្ធិស្របច្បាប់នៃឪពុកម្តាយចំពោះកូនរបស់គាត់ ។

ក្នុងករណីខ្លះ ឪពុកម្តាយអាចស្ម័គ្រចិត្តដោះលែងកូនគេឲ្យយកទៅចិញ្ចឹមដោយចុះហត្ថលេខាលើសំណុំរឿងស្របច្បាប់ហៅថា "ការលះបង់ចោលសិទ្ធិជាភាពនៃឪពុកម្តាយ" ការចុះហត្ថលេខាលើក្រដាសនេះគឺវាជារឿងមួយដ៏ធ្ងន់ធ្ងរដែលគួរតែគិតពីរឿងនេះឲ្យបានប្រយ័ត្នបំផុតហើយធ្វើការពិភាក្សាឲ្យបានពេញលេញជាមួយ CPS អ្នកធ្វើការផ្នែកសង្គមកិច្ចនឹងមេធាវី។

**តុលាការអាចបញ្ឈប់សិទ្ធិរបស់ឪពុកម្តាយដោយគ្មានការអនុញ្ញាតិពេលណា :**

- តុលាការបានសំរេចថាមានការរកអាណាព្យាបាលភាព
- តុលាការបានចេញដីកាបញ្ជាឲ្យធ្វើការកែតម្រូវបញ្ហាដែលបណ្តាលឲ្យមានបណ្តឹងរកអាណាព្យាបាលភាពហើយបញ្ហានៅតែមានដដែល។

- កូនរបស់អ្នកត្រូវបានដាក់ឲ្យថែរក្សានៅក្រៅផ្ទះអស់រយៈពេល 12 ខែ ហើយអ្នកមិនបានធ្វើឲ្យជឿនលឿនគ្រប់គ្រាន់ល្មមដើម្បីអនុញ្ញាតិឲ្យកូនរបស់អ្នកត្រឡប់មកផ្ទះវិញដោយសុខសាន្តនៅពេលអនាគតទេ។
- ការបំរើដែលបញ្ជាដោយតុលាការត្រូវបានផ្តល់ជូន
- មានភវនីយភាពតិចណាស់ដែលថាលក្ខណៈនឹងរីកចំរើនប្រសើរដើម្បីឲ្យក្មេងអាចត្រឡប់មកផ្ទះវិញបាន។
- ការបន្តរទាក់ទងរវាងឪពុកម្តាយនឹងកូននឹងធ្វើឲ្យការរកផ្ទះអចិន្ត្រៃសំរាប់ក្មេងមានការលំបាក់ណាស់។

នៅពេលណាដែលសិទ្ធិរបស់ឪពុកម្តាយត្រូវគេបញ្ឈប់ អ្នកធ្វើការខាង DCFS នឹងធ្វើការរកកន្លែងអចិន្ត្រៃសំរាប់ដាក់ក្មេង។

## តើបុគ្គលម្នួយរូប។អាចធ្វើអ្វីបាន បើមានការមិនយល់ស្របជាមួយ CPS អ្នកធ្វើការខាងសង្គមកិច្ចអំពីការសំរេចចិត្តសំណុំរឿង?

ពិភាក្សាដោយចំហរជាមួយបុគ្គលិក CPS ជូនកាលអាចដោះស្រាយនូវកិច្ចមិនយល់ព្រមនេះបាន។ ប៉ុន្តែបើកិច្ចយល់ព្រមនេះមិនអាចដោះស្រាយបាននៅកំរិតនោះក៏ដោយ បុគ្គលម្នាក់។អចផ្តើមធ្វើដំណើរការតវ៉ាដែលពិភាក្សាពីមុននៅក្នុងកូនសៀវភៅនេះ។

បើការរកអាណាព្យាបាលភាពនេះជាប់ទាក់ទង ឪពុកម្តាយទាំងពីរនឹងកូនក្មេងគួរតែប្រាប់មេធាវីរបស់គេអំពីកិច្ចមិនយល់ព្រមនេះ។ បុគ្គលិក CPS នឹងឲ្យពត៌មាននេះទៅក្រសួងយុត្តិធម៌។

**បើគ្មានដំណោះស្រាយជាមួយនឹងដំណើរការនេះទេ បុគ្គលណាមួយក៏អាចទាក់ទងទៅ:**

■ ការិយាល័យស៊ើបអង្កេតពាក្យបណ្តឹងខាងគ្រួសារនឹងកុមារតាមទូរសព្ទលេខ 1-800-571-7321 ឬផ្នែកអភិបាលកិច្ចកុមារការិយាល័យទំនាក់ទំនងតាមលេខទូរសព្ទ 1-800-723-4831 ។

- បើបុគ្គលនោះជឿថាបញ្ហានេះនឹងបង្ហាញថាបំពានទៅលើសិទ្ធិពលរដ្ឋ ទីភ្នាក់ងារផ្សេងទៀតអាចត្រូវទាក់ទង:

- ការិយាល័យសិទ្ធិពលរដ្ឋ ក្រសួងបំរើសុខភាពនៃមនុស្សកិច្ចនៃសហរដ្ឋអាមេរិកតាមទូរសព្ទលេខ 1-800-362-1710 TDD (206) 615-2296

- គណៈកម្មការខាងសិទ្ធិមនុស្សនៅរដ្ឋវ៉ាស៊ីនតោនតាមទូរសព្ទលេខ 1-800-605-7324 Seattle 1-800-233-3247 Olympia 1-800-662-2755 Yakima ។

- នាយកដ្ឋានផ្នែក Access and Equal នៅរដ្ឋវ៉ាស៊ីនតោនក្រសួងសង្គមកិច្ចនឹងសុខាភិបាល តាមលេខទូរសព្ទ 1-800-521-8060 TDD 1-800-521-8061 ។



គ្រប់ច្បាប់ផ្នែកក្នុង ទម្រង់ការ នឹងសៀវភៅក្បួនទាំងអស់របស់ DCFS ជាឯកសារសាធារណៈហើយអាចពិនិត្យនៅតាមការិយាល័យតាមស្រុកនិមួយៗ។ សូមទូរសព្ទជាមុនហើយដាក់ពេលណាត់ជួបដើម្បីឲ្យជាក់ថាសៀវភៅក្បួនបច្ចុប្បន្នអាចមានហើយមានមនុស្សចាំបង្ហាញខ្លួនដើម្បីឆ្លើយនឹងសំនួរអ្នក។

ច្បាប់ដែលហៅ ច្បាប់កែប្រែ រដ្ឋវ៉ាស៊ីនតោន (RCW) មាននៅក្នុងផ្នែកយោងនៃបណ្ណាល័យធំៗតាមរយៈមេធាវី ឬជួនកាលនៅសាលាកាត់ក្តីតាមខោនធីដែលអនុវត្តន៍ចំពោះ CPS មាននៅក្នុងជំពូកលេខ13.34, 26.44 នឹង 74.13 ។

ជនដែលទាក់ទងដោយផ្ទាល់ជាមួយ CPS ក្នុងការស៊ើបអង្កេតអាចពិនិត្យឡើងវិញនូវសំណុំរឿងរបស់ខ្លួនដោយធ្វើការណាត់ជួប ឬស្នើសុំតាមរយៈការិយាល័យ DCFS នៅកន្លែងអ្នក។ ពត៌មានខ្លះត្រូវលប់ចេញពីសំណុំរឿងនេះមុននឹងពិនិត្យមើលដោយអតិថិជន។

## ច្បាប់នៃពីការមិនរើសអើង

នេះគឺជាច្បាប់ផ្ទៃក្នុងនៃការិយាល័យអភិបាលកិច្ចកុមារដែល  គ្មានជនណាម្នាក់ត្រូវគេរើសអើង បដិសេធពីការចូលរួម ឬបដិសេធពីការទទួលជំនួយពីកម្មវិធី ឬពីសកម្មភាព ឬអ្នកម៉ៅការ ដោយសំអាងលើ ពូជសាសន៍ ពណ៌សម្បុរ សញ្ជាតិដើម គោលជំនឿ សាសនាភេទលក្ខណៈប្ដីប្រពន្ធ អាយុ ឬការប្រើឆ្កែនាំផ្លូវ ឬឆ្កែបំរើដោយជនពិការ។ ការជួយលៃសម្រួលដោយសមរម្យសំរាប់ជនពិការ រួមទាំងអ្នកបកប្រែភាសានឹងសម្ភារៈ ជាទម្រង់ផ្សេងនឹងមានផ្ដល់ជូនទៅតាមសម្នើសុំ។

- អតិថិជនដែលជឿថាត្រូវគេរើសអើងប្រឆាំងដោយការិយាល័យអភិបាលកិច្ចកុមារ អាចដាក់ពាក្យបណ្ដឹងជាមួយទីភ្នាក់ងារដូចខាងក្រោមនេះ។
- ការិយាល័យសិទ្ធិពលរដ្ឋក្រសួងបំរើសុខភាពនៃមនុស្សកិច្ចនៃសហរដ្ឋ អាមេរិកតាមទូរសព្ទលេខ 1-800-362-1710 TDD (206) 615-2296 ។
- គណៈកម្មការខាងសិទ្ធិមនុស្សនៅរដ្ឋវ៉ាស៊ីនតោនតាមទូរសព្ទ លេខ 1-800-605-7324, Seattle; 1-800-233-3247, Olympia; 1-800-662-2755, Yakima។
- នាយកដ្ឋានផ្នែក Access and  Equal នៅរដ្ឋវ៉ាស៊ីនតោនក្រសួងសង្គមកិច្ចនឹង សុខាភិបាល តាមលេខទូរសព្ទ 1-800-521-8060 TDD 1-800-521-8061។

Washington State
Department of Social
& Health Services

DSHS 22-484(X) CA (Rev. 2/00)